អាយុ៣-៥ឆ្នាំ

# ព្រះគម្ពីរសម្រាប់កុមារ មើលតាមរូបភាព

## សៀវភៅអនុវត្ត

សញ្ញាថ្មី២



KIDS GOD WORSHIP
Selan
Ministerio de Publicación Cristiana

# ព្រះគម្ពីរសម្រាប់កុមារមើលតាមរូបភាព

## សៀវភៅអនុវត្ត សញ្ញាថ្មី២

### អាយុ៣-៥ឆ្នាំ

កែសម្រួល kidsworship Selah

បកប្រែដោយ | KOMA Cambodia   រចនាក្រាហ្វិក | Jeewon Park, Julio Blas   ការកែសម្រួល | KOMA Cambodia

ហាមថតចម្លងទាំងស្រុង ឬផ្នែកណាមួយនៃសៀវភៅនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ

# លិបិក្រម




១. ឡាសារអ្នកសុំទាន ........................................ 6

២. លោកសាខេ ........................................ 9

៣. ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម ........................................ 13

៤. ប្រាក់ពីរសេនរបស់ស្ត្រីមេម៉ាយ ........................................ 17

5. ពិធីជប់លៀងចុងក្រោយបំផុត ........................................ 20

៦. ឈើឆ្កាង ........................................ 23

៧. ការមានព្រះជន្មរស់ឡើងវិញ ........................................ 28

៨. ក្រុមជំនុំដើម ........................................ 32

៩. លោកពេត្រុស (លោកពេត្រុសដែលបានប្រោសអ្នកខ្វិនឱ្យជា) ........................................ 36

១០. ការស្លាប់របស់លោកស្ទេផាន ........................................ 40

១១. សាវ័កប៉ុល ........................................ 43

# ចូរកត់ត្រាអំពីដំណើរនៃសកម្មភាព។

ចូរផាត់ពណ៌ បន្ទាប់ពីបញ្ចប់រឿងនីមួយៗ។

ស្កេន QR
ដើម្បីចូលទៅស្តាប់រឿង។





## រឿងទី១៖ ឡាសារអ្នកសុំទាន

**ខគម្ពីរ៖ លូកា១៦:២៥**

លោកអប្រាហាំមានប្រសាសន៍ថា "កូនអើយ! ចូរនឹកចាំថា កាលកូនមានជីវិតនៅឡើយ កូនស្គាល់តែសប្បាយ រីឯឡាសារវិញ គាត់ស្គាល់តែទុក្ខ។ ឥឡូវនេះ ឡាសារបានសុខក្សេមក្សាន្តហើយ តែកូនវិញ កូនត្រូវឈឺចុកចាប់

កាលដើមឡើយ មានអ្នកមានទ្រព្យស្ដុកស្ដម្ភម្នាក់។ គាត់រស់នៅក្នុងផ្ទះប្រណីត និងស្លៀកសំលៀកបំពាក់ថ្លៃៗ។
គាត់បរិភោគអាហារល្អបំផុតជារៀងរាល់ថ្ងៃ ហើយរស់នៅក្នុងភាពប្រណីត។ បុរសអ្នកមានហៅភ្ញៀវមកដើម្បីជប់លៀងនៅផ្ទះគាត់ជារៀងរាល់ថ្ងៃ។
គាត់មិនជឿព្រះទេ គាត់រស់នៅសម្រាប់តែខ្លួនឯង។ នៅមុខផ្ទះបុរសអ្នកមាន មានអ្នកសុំទានម្នាក់ឈ្មោះឡាសារ។
ឡាសារគាត់កើតដំបៅពេញខ្លួន ហើយតែងតែដេកនៅមាត់ទ្វារបងផ្ទះអ្នកមាននោះ។ គាត់ស្លៀកសំលៀកបំពាក់កខ្វក់ ហើយគាត់បរិភោគកម្ទេចអាហារដែលធ្លុះពីតុអ្នកមានមក។ ប៉ុន្តែ ឡាសារជាមនុស្សដែលមានសេចក្ដីជំនឿរឹងមាំលើព្រះ។
ថ្ងៃមួយ ឡាសារក៏បានស្លាប់ទៅ។ ពួកទេវតារបស់ព្រះជាម្ចាស់បាននាំគាត់យកទៅនៅស្ថានបរមសុខ នាដើមទ្រូងលោកអប្រាហាំ ។
រីឯអ្នកមានក៏ស្លាប់ដែរ គេយកសពគាត់ទៅបញ្ចុះក្នុងផ្នូរ។ អ្នកមានធ្លាក់ទៅក្នុងស្ថាននរក ហើយរងទុក្ខទារុណកម្មយ៉ាងខ្លាំង។
ស្ថាននរកជាបឹងភ្លើងដែលឆេះមិនចេះរលត់។ បុរសអ្នកមានបានស្រែកដោយការឈឺចាប់។ គាត់ស្រេកទឹកខ្លាំងណាស់ ហើយបានស្វែងរកទឹក។
ក៏ប៉ុន្តែនៅទីនោះគ្មានទឹកទេ។ បុរសអ្នកមានបានងើយទៅលើ ក៏បានឃើញស្ថានបរមសុខ។
បុរសអ្នកមានភ្ញាក់ផ្អើលយ៉ាងខ្លាំង! គាត់ច្រណែននឹងឡាសារណាស់។ ដូច្នេះ គាត់បានស្រែកអង្វរលោកអប្រាហាំថា៖
«លោកឪពុកអើយ! សូមជួយខ្ញុំផង! រាងកាយខ្ញុំទាំងមូលកំពុងឆេះដោយអណ្ដាតភ្លើង។ វាពិតជាក្ដៅខ្លាំងណាស់! សូមលោកឪពុកប្រាប់ឡាសារឱ្យយកម្រាមដៃជ្រលក់ទឹកបន្តក់លើអណ្ដាតខ្ញុំបន្តិច ព្រោះនៅក្នុងភ្លើងនេះ ខ្ញុំឈឺចុកចាប់ណាស់»។
លោកអប្រាហាំតបថា៖ «កូនអើយ! ឡាសារមិនអាចទៅឯឯងបានឡើយ។ ចូរនឹកចាំថា កាលកូនមានជីវិតនៅឡើយ កូនស្គាល់តែសប្បាយ រីឯឡាសារវិញ គាត់ស្គាល់តែទុក្ខ។ ឥឡូវនេះ ឡាសារបានសុខក្សេមក្សាន្តហើយ តែកូនវិញ កូនត្រូវឈឺចុកចាប់។ ម្យ៉ាងទៀត មានលំហាមួយយ៉ាងធំខណ្ឌយើងពីឯង ទោះបីយើងចង់ឆ្លងពីស្ថាននេះទៅរកឯងក៏ឆ្លងមិនបានឡើយ ទោះបីមានអ្នកណាចង់ឆ្លងពីឯងមករកយើង ក៏ឆ្លងមិនបានដែរ»។
បុរសអ្នកមាន មិនបានជួយឡាសារឡើយ ពេលដែលគាត់នៅរស់។ គឺគាត់មិនចេះស្រឡាញ់អ្នកជិតខាងឡើយ។
អ្នកណាដែលមិនចេះស្រឡាញ់អ្នកជិតខាងដូចបុរសអ្នកមាននេះ មិនអាចក្លាយជាប្រជារាស្ត្ររបស់ព្រះបានឡើយ។
ព្រះយេស៊ូបានបង្រៀនយើងឱ្យស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង។



**សកម្មភាពទី១** សូមគិតពីមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



**សកម្មភាពទី២** សូមហែកក្រដាសពណ៌ យកទៅបិទតុបតែងស្ថានសួគ៌ដែលលោកឡាសារជាអ្នកសុំទាននៅ និងស្ថាននរកដែលអ្នកមាននៅ។



- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ(លូកា១៦:២៥)

ឡាសារបានសុខក្សេមក្សាន្តហើយ តែកូនវិញ កូនត្រូវឈឺចុកចាប់